**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គិសនីកម្ពុជា**
លេខៈ ៤៦០៣ សជណ.ទកឧប

# សេចក្ដីជូនដំណឹង
## ស្ដីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក **ចំនួន ៣៧ រូប** ដើម្បីចូលបម្រើ ការងារនៅអង្គភាពបណ្ដាញបញ្ជូន នៃនាយកដ្ឋានបញ្ជូនអគ្គិសនី ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :

I. បុគ្គលិកល្បាតខ្សែបញ្ជូន នៅតាមបណ្ដាតំបន់ ដូចខាងក្រោម :

១. តំបន់ទី៤ (ខេត្តតាកែវ) : ចំនួន ០១ រូប
២. តំបន់ទី៨ (ខេត្តពោធិ៍សាត់) : ចំនួន ០២ រូប
៣. តំបន់ទី១៦ (អនុស្ថានីយព្រះវិហារទី១-កំពង់ធំ) : ចំនួន ០៤ រូប
៤. តំបន់ទី១៧ (អនុស្ថានីយព្រះវិហារទី១-កំពង់ធំ និងកំពង់ធំ-សៀមរាប) : ចំនួន ០៤ រូប
៥. តំបន់ទី១៨ (អនុស្ថានីយកំពង់ធំ-សៀមរាប និងបាត់ដំបង-សៀមរាប) : ចំនួន ០៤ រូប
៦. តំបន់ទី១៩ (អនុស្ថានីយបាត់ដំបង-សៀមរាប) : ចំនួន ០៤ រូប
៧. តំបន់ទី២០ (អនុស្ថានីយកំពង់ធំ-កំពង់ចាម) : ចំនួន ០៤ រូប
៨. តំបន់ទី២១ (អនុស្ថានីយទី៥-កំពង់ស្ពឺ, កំពង់ស្ពឺ-គីរីរម្យ១ និងគីរីរម្យ១-គីរីរម្យ៣) : ចំនួន ០៤ រូប
៩. តំបន់ទី២២ (អនុស្ថានីយស្ទឹងត្រែង-រតនគិរី) : ចំនួន ០៤ រូប
១០. តំនបន់ទី២៣ (អនុស្ថានីយរតនគិរី-មណ្ឌលគិរី) : ចំនួន ០៦ រូប

- បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ
- មានសុខភាពល្អនិងកាយសម្បទាមាំមួន អាចឡើងបង្គោលតង់ស្យុងខ្ពស់បាន ។

*- **បញ្ជាក់** : ប្រសិនបើលទ្ធផលពិន្ទុ ប្រហាក់ប្រហែលគ្នា គឺត្រូវផ្ដល់អាទិភាពជូនបេក្ខជន មានអាសយដ្ឋានស្ថិតនៅខេត្តសាមី ។

*- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា បេក្ខជនត្រូវទាញយក **(Download)** ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : **www.EDC.com.kh** ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើ ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា ។

*- បេក្ខជនត្រូវបំពេញពាក្យសុំចូលបម្រើការងារ និងត្រូវអញ្ជើញមកដាក់ពាក្យប្រឡងដោយផ្ទាល់ខ្លួន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ច្បាប់ដើមមកជាមួយ ។ ករណី បេក្ខជនមិនបានអញ្ជើញមកដាក់ពាក្យដោយផ្ទាល់ទេ អគ្គិសនីកម្ពុជា មិនទទួលពាក្យជូនឡើយ ។

***- បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ :**

- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ ចំនួន ០១ ច្បាប់
- សលាកប័ត្របេក្ខជន ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ ចំនួន ០១ ច្បាប់
- តារាងពិន្ទុ (TRANSCRIPT) ចំនួន ០១ ច្បាប់
- ច្បាប់ដើម និងច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ចំនួន ០១ ច្បាប់

***- ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធI នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។**

*- **ទីកន្លែងទទួលពាក្យ** : **នៅអគារ B ជាន់ទី១ ការិយាល័យបុគ្គលិក នៃអគ្គិសនីកម្ពុជា**

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០ ។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

ថ្ងៃ ច័ន្ទ ១៤ រោច ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩

ជ. **រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**អគ្គនាយកអគ្គិសនីកម្ពុជា**

**អគ្គនាយករង**

ELECTRICITE DU CAMBODGE

អេង_គន្ធា

**បញ្ជាក់**

- សេចក្តីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ "។